# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកីរីសាគរ កោះកុង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលលើមាត្រា ៤ ចំណុច ៤.១ និងចំណុច ៤.៣ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**សម្រេច**

**មាត្រា១** : បង្កើត **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** ( KIRISAKOR KOH KONG S E Z ) ដែលមានទីតាំងស្ថិតនៅឃុំព្រែកខ្សាច់ និងឃុំជីខាលើ ស្រុកគីរីសាគរ និងឃុំប៉ាក់ខ្លងប្រែស ស្រុកកោះកុង ខេត្តកោះកុង ។

**មាត្រា២** : **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** ផ្នែក ក និង ខ មានទំហំ ពីរពាន់ ពីររយ ហិកតា និងបុកសិបប្រាំ អា ដូចមានប្លង់ទីតាំងភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣** : ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤** : ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកោះកុង និងក្រុមហ៊ុន កោះកុង អេស អ៊ី ហ្សិត ខូ អិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ




តារាងនិយាមការនៃចំណុចព្រំប្រទល់

Projection UTM, Zone 48N, Datum WGS 84.

| Points ID | Northing (m) | Easting (m) | Points_ID | Northing (m) | Easting (m) |
|---|---|---|---|---|---|
| ចំណុច ក | | | 33 | 1242600.094 | 293530.199 |
| 1 | 1241480.328 | 289700.238 | 34 | 1243863.142 | 293807.248 |
| 2 | 1241276.470 | 288800.067 | 35 | 1243724.303 | 294551.030 |
| 3 | 1240780.472 | 288026.630 | 36 | 1242420.585 | 294197.300 |
| 4 | 1240623.134 | 287379.198 | 37 | 1243230.230 | 295224.987 |
| 5 | 1241374.673 | 218687.171 | 38 | 1243222.459 | 295520.990 |
| 6 | 1241486.243 | 287610.438 | 39 | 1243323.950 | 295818.101 |
| 7 | 1242124.801 | 287773.369 | 40 | 1239949.850 | 295728.545 |
| 8 | 1242067.053 | 287438.723 | 41 | 1239091.073 | 295385.434 |
| 9 | 1242053.098 | 287872.110 | 42 | 1238977.314 | 295115.521 |
| 10 | 1242071.757 | 287784.730 | 43 | 1239255.194 | 295130.281 |
| 11 | 1242424.578 | 287790.546 | 44 | 1239425.468 | 295209.104 |
| 12 | 1242767.005 | 288081.406 | 45 | 1239608.298 | 294701.091 |
| 13 | 1242910.123 | 288743.703 | 46 | 1239224.073 | 294462.006 |
| 14 | 1242868.768 | 288922.674 | 47 | 1240072.822 | 294250.510 |
| 15 | 1242885.507 | 289085.478 | 48 | 1240183.846 | 293074.898 |
| 16 | 1242573.869 | 288360.613 | 49 | 1240187.358 | 292790.075 |
| 17 | 1242984.433 | 289590.560 | 50 | 1240168.168 | 293407.987 |
| 18 | 1242717.828 | 289678.528 | 51 | 1240131.111 | 293178.673 |
| 19 | 1242527.038 | 289463.034 | 52 | 1240115.007 | 292423.416 |
| 20 | 1242047.621 | 289658.873 | 53 | 1241148.165 | 291144.838 |
| ចំណុច ខ | | | ចំណុច គ | | |
| 21 | 1242001.157 | 289858.809 | 30 | 1243325.485 | 295614.101 |
| 22 | 1242532.965 | 289863.002 | 54 | 1244187.439 | 298442.413 |
| 23 | 1242738.585 | 289801.467 | 55 | 1243913.412 | 298960.413 |
| 24 | 1242886.916 | 289441.251 | 56 | 1241782.039 | 311882.027 |
| 25 | 1242768.230 | 289340.752 | 57 | 1236990.370 | 312344.125 |
| 26 | 1242977.820 | 289065.129 | 58 | 1236080.368 | 301182.420 |
| 27 | 1243440.322 | 291934.406 | 59 | 1237531.706 | 300132.367 |
| 28 | 1243048.029 | 292453.327 | 60 | 1237566.742 | 299419.400 |
| 29 | 1243231.805 | 292595.864 | 61 | 1238134.184 | 296075.062 |
| 30 | 1243236.402 | 293020.577 | 62 | 1237932.092 | 296097.360 |
| 31 | 1243412.257 | 293347.541 | 40 | 1239940.850 | 295728.545 |
| 32 | 1243617.438 | 293391.039 | | | |

289500 296000 302500 309000

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៨

ភ្នំពេញ, ថ្ងៃទី

ប្រធាន




ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៨
ប្រធានក្រុមវាស់វែង

ឈុំ សោភណ៌

បានត្រឹមត្រូវ
ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៨
មេបញ្ជាការ...

ឡុង ដារ៉ុន